01122386

E352/L

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 07 / 2015
ម៉ោង (Time/Heure) : 11:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការបញ្ជាក់ពីការទទួលបានញត្តិ

1. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ឧបសម្ព័ន្ធ ដែលបញ្ជាក់អំពីគម្រោងសំណងដែលកំពុងត្រូវបានបង្កើតឡើងនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E352, ឯកសារ E352.2)។ ការដាក់របាយការណ៍បណ្តោះអាសន្ននេះគឺក្នុងគោលបំណងផ្តល់ជាព័ត៌មានប៉ុណ្ណោះ ហើយមិនតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចអ្វីឡើយ។

2. សហមេធាវីនាំមុខក៏បានភ្ជាប់ញត្តិមួយដែលមានចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណីច្រើននាក់ដែលស្នើសុំសំណងជាប្រាក់នៅក្នុងសំណុំរឿង ០០២ (ឯកសារ E352.4)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យ "អង្គជំនុំជម្រះបញ្ជាក់ពីការទទួលបានញត្តិទាមទារសំណងជាប្រាក់ជាលក្ខណៈបុគ្គលនេះ" ដើម្បី "ឆ្លើយតបទៅនឹងការរំពឹងទុករបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយធ្វើឲ្យពួក

គាត់មានអារម្មណ៍ថាបានបញ្ចប់បញ្ហា និង ដើម្បីបង្ហាញពីទស្សនៈរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី" (ឯកសារ E352 កថាខណ្ឌ ១៧ និង ទំព័រ ១១)។ ញត្តិនេះត្រូវបានដាក់ចូលក្នុងសំណុំរឿងត្រឹមត្រូវហើយ ហើយបច្ចុប្បន្ននេះ ញត្តិនេះមាននៅក្នុងសំណុំរឿង ០០២។ ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីម្ដងទៀតថា អ.វ.ត.ក ពុំមានយុត្តាធិការបង្គាប់ឱ្យមានការអនុវត្ត ឬ ចេញសំណងជំងឺចិត្តជាប្រាក់បានឡើយ។ អង្គជំនុំជម្រះអាចសម្រេចផ្ដល់ឱ្យបានតែសំណងផ្លូវចិត្ត និង ជាសមូហភាពប៉ុណ្ណោះ (ឯកសារ E313 កថាខណ្ឌ ១១១៤-១១៦)។ លើសពីនេះទៀត នៅក្នុងដំណាក់កាលជំនុំជម្រះដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមដោយរួមបញ្ចូលគ្នាជាក្រុមបណ្ដុំតែមួយ ដែលតំណាងដោយសហមេធាវីនាំមុខ (ឯកសារ E313 កថាខណ្ឌ ១១១០)។ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ និង មេធាវីរបស់ពួកគាត់ពុំមានសិទ្ធិធ្វើសេចក្ដីសន្និដ្ឋាននៅចំពោះមុខអង្គជំនុំជម្រះឡើយ។

3. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E352។